**សេចក្តីប្រកាសព័ត៌មាន**

*ថ្ងៃ ពុធ ៩រោច ខែ កត្តិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៩*

## កិច្ចប្រជុំ

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារបច្ចេកទេស (TWG) ស្តីពី

## ការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៩

## (ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩)

នាព្រឹកថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស), មានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស (Technical Working Group - TWG) ដែលមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័ន, តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ។ កិច្ចប្រជុំនេះ ផ្តោតសំខាន់លើការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានអនុវត្តក្នុងដំណាក់កាលទី ៣ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៩ ។

តាមរយៈរបាយការណ៍បូកសរុប, រហូតមកដល់ត្រីមាសទី ៣ នេះ គ្រប់ផ្នែកនៃផែនការសកម្មភាពរួមនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅបន្តមានវឌ្ឍនភាពល្អ និងវិជ្ជមាន ។ ក្នុងរយៈពេល ៩ ខែនេះ, រាជរដ្ឋាភិបាលកម្ពុជា បានប្រមូលចំណូលថវិការដ្ឋសរុបប្រមាណ ១៩ ១២៥ ប៊ីលានរៀល ស្មើនឹង ៩០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៩ ។ ការអនុវត្តផែនការប្រមូលចំណូលប្រចាំត្រីមាសទី ៣ បង្ហាញថា ទិន្នផលចំណូលបានពីការប្រមូលដោយពន្ធគយនិងរដ្ឋាករ មានប្រមាណ ៤៩%, ពន្ធដារ មានប្រមាណ ៣២%, ចំណូលមិនមែនសារពើពន្ធមានប្រមាណ ១២% និងចំណូលផ្សេងៗប្រមាណ ៦% ។ រីឯការអនុវត្តចំណាយស្ថិតក្នុងស្ថានភាពដែលអាចគ្រប់គ្រងបានតាមច្បាប់ជាធរមាន ។ សម្រាប់ការអនុវត្តសកម្មភាពនៃការងារកែទម្រង់ ទាំងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជា ក្របខ័ណ្ឌក្រសួង-ស្ថាប័ន កំពុងបន្តមានវឌ្ឍនភាពល្អប្រសើរ ដែលត្រូវបានរំពឹងទុកថាអាចសម្រេចបានគោលដៅប្រចាំឆ្នាំ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ថា ការប្រមូលចំណូល និងការអនុវត្តចំណាយ នៅបន្តមានសុខភាពល្អធៀបនឹងឆ្នាំមុនៗ និងនៅរក្សាបាននិន្នាការល្អប្រសើរទៅតាមការគ្រោងទុក ។ ស្របពេលជាមួយគ្នានេះ, កិច្ចការគន្លឹះៗមួយចំនួនទៀត ត្រូវបន្តពង្រឹងក្នុងការអនុវត្ត កសាង និងរៀបចំបញ្ចប់ រួមមាន÷ ការរៀបចំបញ្ចប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះៗនានា ដូចជា យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, និងអនុក្រឹត្យស្តីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈជាដើម ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានផ្តល់អនុសាសន៍ណែនាំបន្ថែមលើការពង្រឹងសមត្ថភាពមន្ត្រី ដោយត្រូវគិតគូររៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ តាមរយៈការបន្តបណ្តុះបណ្តាលដែលជាក់លាក់ ប្រកបដោយគុណភាព ក៏ដូចជាបំពាក់ជំនាញច្បាស់លាស់ និងប្រើប្រាស់ធនធានដែលបានបណ្តុះបណ្តាលឱ្យត្រូវតាមតួនាទី និងភារកិច្ច និងជំនាញនីមួយៗ ។

ជាមួយគ្នានេះ, **តំណាងដៃគូអភិវឌ្ឍន៍** បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលសម្រេចបានក្នុងត្រីមាសទី ៣ និងការខិតខំប្រឹងប្រែងអនុវត្តការងារកែទម្រង់យ៉ាងសកម្មពីក្រសួង-ស្ថាប័ន ទាំងអស់ ។ **ដៃគូអភិវឌ្ឍន៍** ក៏បានផ្តល់អនុសាសន៍បន្ថែម ជាពិសេស ទៅលើប្រសិទ្ធភាពនៃការអនុវត្តចំណាយរបស់ក្រសួង-ស្ថាប័ន, ការប្រើប្រាស់ប្រព័ន្ធ (Financial Management Information System - FMIS) និងពង្រឹងការផ្សព្វផ្សាយលើការត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធី ។ បន្ថែមពីនេះ, ដៃគូអភិវឌ្ឍន៍ នៅតែបន្តផ្តល់ការសហការល្អ និងកិច្ចគាំទ្រ ទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ទៅលើសកម្មភាពគន្លឹះសំខាន់ៗរបស់ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅកម្ពុជានេះ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះអនុសាសន៍ដែលជាធាតុចូលបន្ថែមរបស់ដៃគូអភិវឌ្ឍន៍ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ កោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ខ្ពស់របស់ដៃគូរអភិវឌ្ឍន៍ដែលបានចូលរួមសហការ និងធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើស្មារតីដែលកម្ពុជា ជាម្ចាស់លើការដ្ឋានការងារកែទម្រង់នេះ ដែលធាតុចូលបន្ថែមរបស់ដៃគូអភិវឌ្ឍន៍ ឆ្លើយតបទៅនឹងតម្រូវ និងសភាពការជាក់ស្តែងរបស់កម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើ និងលើកទឹកចិត្តឱ្យមន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន ទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ៕